ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

លេខ:៣៨៦/២៥-០៤-២០១១

សាលដីកា

លេខ:២៥ ក្រIVត/០៣-៤-២០១៤

តាងនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី៣១ ខែ មិនា ឆ្នាំ២០១៤ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍រឿងព្រហ្មទណ្ឌលេខ ៣៨៦ ចុះថ្ងៃទី២៥-០៤-២០១១ រវាង:

១-ជនជាប់ចោទឈ្មោះ [redacted] សុខុម ភេទស្រី អាយុ៥២ ជនជាតិខ្មែរ មុខរបរកសិករ មានទីលំនៅ [redacted] ឪពុកឈ្មោះ [redacted] ស) ម្តាយឈ្មោះ នៅ [redacted] (ស) ប្តីឈ្មោះ [redacted] (ស) មានកូន៤នាក់ ទោសពីមុនគ្មាន (ដើមបណ្តឹងឧទ្ធរណ៍) ឃុំខ្លួននៅថ្ងៃទី០៨-៤-២០១០ ។ លោក [redacted] ម៉ាច ជាមេធាវីការពារ

២-ជនជាប់ចោទឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ មានទីលំនៅភូមិ [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន (ដើមបណ្តឹងឧទ្ធរណ៍) ឃុំខ្លួនថ្ងៃទី០៨-៤-២០១០

- លោក [redacted] វិបុល ជាមេធាវីការពារ។

ត្រូវចោទពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅព្រែកតាកែវ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១០ ។/

៣៦





Scanned with CamScanner

បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា០៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

**៦រឿងហេតុមានដូចតទៅៈ**

តាមរបាយការណ៍របស់សមត្ថកិច្ចបានបញ្ជាក់ថា កាលពីថ្ងៃទី០២-០៤-២០១០ ម៉ោង១០ព្រឹក ជនសង្ស័យពីរនាក់ម្តាយនិងកូន បានពិភាក្សាគ្នា ក្នុងការសម្លាប់ជនរងគ្រោះ ដែលត្រូវជាប្តីនិងត្រូវជាឪពុក ។ លុះដល់ថ្ងៃទី០៦-០៤-២០១០ វេលាម៉ោង១,០០នាទីអាធ្រាត ជនសង្ស័យត្រូវជាកូនជនរងគ្រោះបានយកកាំបិតទៅកាប់ជនរងគ្រោះជាឪពុកជាច្រើនកាំបិត បណ្តាលឲ្យស្លាប់តែម្តង ។

លុះដល់ថ្ងៃទី០៧-០៤-២០១០ ម៉ោង១២និង០០នាទី កម្លាំងនគរបាលស្រុកកៀនស្វាយ បានធ្វើការឃាត់ខ្លួនជនសង្ស័យ ទាំងពីរនាក់ម្តាយ និងកូន ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១៥ (ស) ចុះថ្ងៃទី០២-០៣-២០១១ របស់សាលាដំបូងខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សុខុម ភេទស្រី អាយុ៥២ ជាតិខ្មែរ និងឈ្មោះ ម៉ែន វាសនា ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ចំនួន១៥ឆ្នាំ ពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិព្រែកតាកែវ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី០៦-០៤-២០១០ គិតពីថ្ងៃចាប់ខ្លួន ថ្ងៃទី០៧-០៤-២០១០ ។

បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឲ្យផ្តន្ទាទោស តាមមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-វត្ថុតាងៈ កាំបិតផ្គាក់មួយ ដងឫស្សីមានរុំខ្សែជ័រពណ៌សរ រឹបអូសជាសម្បត្តិរដ្ឋ ។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២១-០៣-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] វាសនា ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ១៥ (ស) ចុះថ្ងៃទី០២-០៣-២០១១ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] សុខុម , ឈ្មោះ [redacted] វាសនា(អវត្តមាន)

ប្រធានក្រុមប្រឹក្សាៈ អានរបាយការណ៍ បញ្ជាក់អង្គហេតុនៃរឿង

ក្រឡាបញ្ជី អានចម្លើយឈ្មោះ [redacted] សុខុម , [redacted] វាសនា នៅសមត្ថកិច្ចនិងនៅចៅក្រមស៊ើបសួរ

ប្រធានក្រុមប្រឹក្សាៈ អានលិខិតរបស់មន្ទីរពេទ្យ បញ្ជាក់ពីស្ថានភាពជម្ងឺរបស់ [redacted] សុខុម

តំណាងមហាអយ្យការផ្តល់សេចក្តីសន្និដ្ឋានៈ

ក្រោយពីពិនិត្យសំណុំរឿងឃើញថា ចម្លើយជនជាប់ចោទមានការប្រែប្រួលខ្លះ បើពិនិត្យសាលក្រមសំអាងហេតុ និងសេចក្តីសម្រេចត្រឹមត្រូវហើយ សុំក្រុមប្រឹក្សាពិនិត្យ និងសម្រេចតាមច្បាប់ ។

មេធាវី [redacted] ម៉ាច ផ្តល់សេចក្តីសន្និដ្ឋានៈ ៤

៣៤



Scanned with CamScanner

មូលហេតុដោយសារប្ដីផឹកស្រាវាយប្រពន្ធ ហើយកូនក្ដីខ្លួនឈ្មោះ [redacted] សុខុម សភាពជម្ងឺគាត់ធ្ងន់ធ្ងរណាស់ហើយរឿងនេះឈានដល់ដំណាក់កាលនេះ គឺមកពីប្ដីផឹកស្រារាល់ថ្ងៃធ្វើឲ្យគាត់ទ្រាំមិនបាន ។ បើពិនិត្យមើលអំពើឃាតកម្ម សំណុំរឿងត្រូវមានកោសល្យវិច័យ គ្មានឃើញស្នាមកាំបិតនិងថា ត្រូវគេបំពុល ហើយបើតាមចម្លើយកូនក្ដីខ្លួនថា ប្ដីគាត់ប្រកាច់ធ្លាក់ទឹកប្រឡាយ ឯចម្លើយកូនថា ឪពុកនោះផឹកថ្នាំពុល ។ សំណូមពរសុំក្រុមប្រឹក្សាផ្ដល់ ស្ថានសំរាលដល់គាត់ ។

មេធាវី [redacted] វិបុល ផ្ដល់សេចក្ដីសន្និដ្ឋាន:

តាមការពិនិត្យសំណុំរឿងឃើញថា ចម្លើយមានការប្រែប្រួល ថាឪពុកស្លាប់ដោយគេបំពុល ។ សពត្រូវបានយកទៅធ្វើបុណ្យភ្លាមៗ ក្រោយពីមានក្មេងម្នាក់ប្រាប់ ។ កូនក្ដីខ្លួនឈ្មោះ [redacted] វាសនា ត្រូវផ្ដន្ទាទោស ១៥ឆ្នាំ ហើយតាមការពិនិត្យសំណុំរឿងឃើញថា ចម្លើយកូនក្ដីខ្លួនមានការប្រែប្រួលដូចលោកមេធាវីការពារជនជាប់ចោទម្នាក់ទៀតបញ្ជាក់ ខ្លួនសូមឯកភាពតាម ហើយរឿងនេះគ្មានកំណត់ហេតុពិនិត្យសាកសពទេ ដោយស្លាប់ភ្លាមហៅអាចារ្យធ្វើបុណ្យភ្លាមៗ ។ សមត្ថកិច្ចហៅកូនក្ដីខ្លួនសាកសួរពីរឿងស្នាមមុតបន្លាទើបពាក់ព័ន្ធរឿងនេះ ។ សំណូមពរសុំក្រុមប្រឹក្សាពិចារណាសម្រេចតាមច្បាប់ ។

-ក្រោយពីបានស្ដាប់ការអានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាល្អិតល្អន់ត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

១-បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២១-០៣-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] វាសនា និងឈ្មោះ [redacted] សុខុម ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ១៥(ស) ចុះថ្ងៃទី០២-០៣-២០១១ របស់សាលាដំបូងខេត្តកណ្ដាល ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

២-ជនជាប់ចោទបានបដិសេធនាពេលសវនាការ ប៉ុន្តែបានឆ្លើយសារភាពនៅចំពោះមុខនគរបាល និងនៅចំពោះមុខចៅក្រមស៊ើបសួរ លើចំណុចដែលបានធ្វើសកម្មភាពកាប់លើជនរងគ្រោះដោយផ្ទាល់ ដែលមានលក្ខណៈស៊ីសង្វាក់គ្នា ។

៣-ជនជាប់ចោទជាប្រពន្ធនិងកូន បានប្រព្រឹត្តអំពើឃាតកម្ម ដោយសារឪពុកជាអ្នកប្រមឹកវាយធ្វើបាបប្រពន្ធ កូន ពេលស្រវឹងមានរយៈពេលយូរ រហូតដល់មិនអាចអត់ទ្រាំបាន ទើបសម្រេចចិត្តធ្វើបែបនេះឃើញថាកាលៈទេសៈជំរុញឲ្យប្រព្រឹត្តបទល្មើសដោយជនរងគ្រោះ គប្បីតុលាការពិចារណាស្ថានសម្រាលតាមមាត្រា៩៣ ៩៤នៃក្រមព្រហ្មទណ្ឌ ។

៤-សាលក្រមព្រហ្មទណ្ឌលេខ១៥ (ស) ចុះថ្ងៃទី០២-០៣-២០១១ របស់សាលាដំបូងខេត្តកណ្ដាល បានសម្រេចត្រឹមត្រូវហើយ គប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមខាងលើទុកជាបានការ លើកលែងតែចំណុចទី១នៃសេចក្ដីសម្រេចដែលត្រូវកែតម្រូវតាមការយល់ឃើញខាងលើ ។

**វិនិច្ឆ័យសេចក្ដី**

១-ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២១-០៣-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] វាសនា និងឈ្មោះ [redacted] សុខុម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១៥ (ស) ចុះថ្ងៃទី០២-០៣-២០១១ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការ លើកលែងតែចំណុចទី១នៃសេចក្តីសម្រេចត្រង់ - ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សុខុម និង ឈ្មោះ [redacted] វាសនា ដាក់ពន្ធនាគារម្នាក់ៗ ១៥ឆ្នាំ - ត្រូវកែប្រែជា - ផ្តន្ទាទោសឈ្មោះ [redacted] សុខុម ដាក់ពន្ធនាគារ១០ឆ្នាំ (ដប់ឆ្នាំគត់) និង ឈ្មោះ [redacted] វាសនា ១៣ឆ្នាំ (ដប់បីឆ្នាំគត់) -វិញ។ ចំណុចផ្សេងទៀតនៅរក្សាទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទខាងលើតាមនីតិវិធី ។

សាលដីកានេះជំនុំជំរះជាសាធារណៈចំពោះមុខមេធាវីការពារជនជាប់ចោទ និង កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] វាសនា និងឈ្មោះ [redacted] សុខុម ប្រកាសជាសាធារណៈ នៅថ្ងៃទី០៣-០៤-២០១៤ បើកសិទ្ធិប្តឹងទាស់ និង ប្តឹងសាទុក្ខក្នុងរយៈពេលដែលច្បាប់កំណត់ ។

សាលដីកានេះចូលជាស្ថាពរលើជនជាប់ចោទឈ្មោះ [redacted] សុខុម ម្នាក់ប៉ុណ្ណោះ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកានិងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែងជួយសហការអនុវត្តសាលដីកានេះអោយបានសម្រេចបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]



Scanned with CamScanner